# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៤៨

## ស្ដីពី

## ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ
## នៃព្រះរាជាណាចក្រកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្ដិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៤

**ត្រាស់បង្គាប់**

Downloaded from http://www.khmerlaws.com

**មាត្រា ១.-**

បង្កើតឱ្យមានមូលនិធិមួយដើម្បីជួយអភិវឌ្ឍន៍អគ្គិសនីជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះថា "មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ" សរសេរកាត់ថា "**ម.អ.ជ.**" ។

**មាត្រា ២.-**

**ម.អ.ជ.** ត្រូវបង្កើតឡើងដាច់ដោយឡែក ជាស្ថាប័នសាធារណៈស្វយ័តមានលក្ខណៈសង្គមកិច្ច ហើយមានស្វ័យភាពក្នុងការគ្រប់គ្រងរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់នៃព្រះរាជាណា ចក្រកម្ពុជា ។

**មាត្រា ៣.-**

គោលបំណងនៃការបង្កើត **ម.អ.ជ.** គឺ ÷

១- ជំរុញឱ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឱ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃដែលអាចជាវបានសំរាប់សេដ្ឋកិច្ច សង្គម និងលំនៅស្ថានរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

២- ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឱ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅជនបទ ប្រកបដោយចីរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថាមពលថ្មី និងថាមពលកកើតឡើងវិញដែលមានលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្មសមស្រប ។

**មាត្រា ៤.-**

**ម.អ.ជ.** ត្រូវគ្រប់គ្រងដឹកនាំដោយក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃ **ម.អ.ជ.** ត្រូវកំណត់ដោយលក្ខន្តិកៈ ដែលនឹងត្រូវរៀបចំនិងសំរេចដោយក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។

សមាសភាពក្រុមប្រឹក្សាភិបាល **ម.អ.ជ.** មានជាអាទិ៍ ÷

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | ជាប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | ជាអនុប្រធាន |
| ៣. រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង | ជាអនុប្រធាន |
| ៤. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៥. តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦. ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ឬតំណាង | ជាសមាជិក |



Downloaded from http://www.khmerlaws.com

៧. តំណាងក្រុមអ្នកផ្តល់ជំនួយដែលក្រុមនេះបានស្នើទៅរដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជាសមាជិក

៨. តំណាងផ្នែកហិរញ្ញវត្ថុដែលសមាគមធនាគារិកកម្ពុជា
បានស្នើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៩. តំណាងក្រុមហ៊ុនដែលបានចូលរួមក្នុងគំរោងអភិវឌ្ឍន៍អគ្គិសនីជនបទ
ដែលបានស្នើទៅ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

១០.តំណាងអង្គការក្រៅរដ្ឋាភិបាល ឬអង្គការអន្តរជាតិដែលបានចូលរួម
ក្នុងគំរោងអភិវឌ្ឍន៍ អគ្គិសនីជនបទ ដែលបានស្នើទៅរដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

១១.តំណាងមួយរូបរបស់អ្នកប្រើប្រាស់អគ្គិសនីជនបទ ជាសមាជិក

តំណាងនេះអាចជាសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់មួយរូប ក្នុងករណីដែលពុំទាន់មាន តំណាងអ្នកប្រើប្រាស់អគ្គិសនីជនបទ ។

សមាជិកក្រុមប្រឹក្សាភិបាលមានអាណត្តិរយៈពេលពីរឆ្នាំ ហើយនៅពេលចប់អាណត្តិអាចបន្តបានតែម្តងទៀតសំរាប់រយៈពេលពីរឆ្នាំ ។

**មាត្រា ៥.-**

ប្រភពផ្តល់មូលនិធិដល់ **ម.អ.ជ.** មានដូចខាងក្រោម ÷

១. អំណោយ និងជំនួយឥតសំណង ដែលប្រភពនិងល័ក្ខខ័ណ្ឌនៃការផ្តល់ ត្រូវបានទទួលការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២. ប្រភពដទៃទៀតពីរាជរដ្ឋាភិបាលដែលមានលក្ខណះទៀងទាត់ និងសមស្របក្នុងការអនុវត្តនូវគោលនយោបាយ និងគោលដៅអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ ។

**មាត្រា ៦.-**

**ម.អ.ជ.** អនុវត្តភារកិច្ចរបស់ខ្លួន រហូតដល់ពេលដែលគោលនយោបាយអគ្គិសនីភាវូបនីយកម្មជនបទ សំរេចគោលដៅដែលបានកំណត់ ។

**មាត្រា ៧.-**

ដោយមិនឱ្យហួសពីរយៈពេលបីខែបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃព្រះរាជក្រឹត្យនេះ នាយករដ្ឋមន្ត្រី តែងតាំងប្រធាន អនុប្រធាន និងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។



Downloaded from http://www.khmerlaws.com

រាជរដ្ឋាភិបាលត្រូវផ្តល់មូលនិធិដំបូងតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទៅឱ្យ **ម.អ.ជ.** សំរាប់កិច្ចប្រតិបត្តិការនៅពេលតែងតាំងក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។ **ម.អ.ជ.** ត្រូវតំកល់ប្រាក់នេះក្នុងគណនីដោយឡែកសំរាប់ប្រើការ ។ មានតែ **ម.អ.ជ.** ប៉ុណ្ណោះដែលមានសិទ្ធិប្រើប្រាស់ប្រាក់តំកល់នេះ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវផ្ទេរមុខងារ និងភារកិច្ចកំណត់ឱ្យដោយព្រះរាជក្រឹត្យនេះឱ្យទៅ **ម.អ.ជ.** ភ្លាមពេលដែល **ម.អ.ជ.** ដំណើរការពេញលេញ ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច តាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១០.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៖រ.ល.០៤១២.០៤៨

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា**
**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

លេខ: ៧១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាង៉ី តាន់



Downloaded from http://www.khmerlaws.com